ក

# មាតិកា

## I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១.ព្រះរាជក្រម


២០-៦-២០០៩ -ព្រះរាជក្រម នស/រកម/០៦០៩/០០៨ ស្តីពីការភតិសន្យាហិរញ្ញវត្ថុ ៤១៤២


### ២.ព្រះរាជក្រឹត្យ


៣០-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ៤១៥៨

៣០-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០៩ ស្តីពីការបញ្ចូលលោក **គង់ ទិមាន** ទៅក្នុងឋានន្តរសក្តិវរមន្ត្រីថ្នាក់ លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងអភិវឌ្ឍន៍ជនបទ ៤១៦៥

៣០-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦១១ ស្តីពីការតែងតាំងទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០៤ រូប ៤១៦៧

០២-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦១២ ស្តីពីការតម្លើងថ្នាក់ ក្នុងឋានន្តរសក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ ក្រសួង ស្ថាប័ន ចំនួន ០៥ រូប ៤១៦៨

០២-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦១៣ ស្តីពីការកែសម្រួលមាត្រា ៤ ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ **អប្សរា** ៤១៧០

០២-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦១៤ ស្តីពីការតែងតាំងឥស្សរជនចំនួន ០៧ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៤១៧៣

០២-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦១៥ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម **ឈៅ ឆួក** នូវគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ៤១៧៤


## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


១១-៦-២០០៩ -អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ៤១៧៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និង ទណ្ឌិត ៤១៨១

អនុក្រឹត្យលេខ ៧៧៥ អនក្រ.តត ដល់ ៧៨០ អនក្រ.តត (**មិនទាន់បានទទួល**)

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨១ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកពេជ្រាដា នៃខេត្ត មណ្ឌលគិរី ៤១៨៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨២ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកអូររាំង នៃខេត្ត មណ្ឌលគិរី ៤១៨៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨៣ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ក្រុងសែនមនោរម្យ នៃខេត្ត មណ្ឌលគិរី ៤១៩១

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨៤ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកោះញែក នៃខេត្ត មណ្ឌលគិរី ៤១៩៣

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨៥ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកែវសីមា នៃខេត្ត មណ្ឌលគិរី ៤១៩៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨៦ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកអណ្តូងមាសនៃខេត្ត រតនគិរី ៤១៩៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨៧ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកបរកែវនៃខេត្ត រតនគិរី ៤១៩៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨៨ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកកូនមុំនៃខេត្ត រតនគិរី ៤២០១

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨៩ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ក្រុងបានលុងនៃខេត្ត រតនគិរី ៤២០៣

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩០ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកលំផាត់នៃខេត្ត រតនគិរី ៤២០៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩១ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកអូរជុំនៃខេត្ត រតនគិរី ៤២០៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩២ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកអូរយ៉ាដាវនៃខេត្ត រតនគិរី ៤២០៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩៣អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកតាវែងនៃខេត្ត រតនគិរី ៤២១១

# ឥ


២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩៤ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកវើនសៃនៃខេត្ត
រតនគិរី ៤២១៣

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩៥ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខណ្ឌ ឬស្សីកែវ នៃរាជ
ធានីភ្នំពេញ ៤២១៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩៦ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខណ្ឌ សែនសុខ នៃរាជ
ធានីភ្នំពេញ ៤២១៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩៧ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខណ្ឌ ដង្កោ នៃរាជ
ធានីភ្នំពេញ ៤២១៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩៨ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខណ្ឌ ៧មករា នៃរាជ
ធានីភ្នំពេញ ៤២២១

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៩៩ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខណ្ឌ ដូនពេញ នៃរាជ
ធានីភ្នំពេញ ៤២២៣

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០០ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខណ្ឌ ទួលគោក នៃរាជ
ធានីភ្នំពេញ ៤២២៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០១ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខណ្ឌ ចំការមន នៃរាជ
ធានីភ្នំពេញ ៤២២៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០២ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខណ្ឌ មានជ័យ នៃរាជ
ធានីភ្នំពេញ ៤២២៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០៣ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ក្រុងប៉ោយប៉ែតនៃខេត្ត
បន្ទាយមានជ័យ ៤២៣១

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០៤ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកម៉ាឡៃ នៃខេត្ត
បន្ទាយមានជ័យ ៤២៣៣

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០៥ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកអូរជ្រៅ នៃខេត្ត
បន្ទាយមានជ័យ ៤២៣៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០៦ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ក្រុង សិរីសោភ័ណ
នៃខេត្តបន្ទាយមានជ័យ ៤២៣៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០៧ អនក្រ.បក ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកស្វាយចេកនៃខេត្ត
បន្ទាយមានជ័យ ៤២៣៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០៨ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុក ថ្មពួកនៃខេត្ត
បន្ទាយមានជ័យ ៤២៤១

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០៩ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុក ភ្នំស្រុក នៃខេត្ត
បន្ទាយមានជ័យ ៤២៤៣

## ២. សារាចរ

២៨-៥-០៩ - សារាចរលេខ ០៣ សរ ស្តីពីការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣
( ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ) ៤២៤៥

# III. ការិយាល័យក្រសួង

## ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១០-១០-២០០៨-លិខិតបញ្ជាក់លេខ ៥៤៨៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន**ផស៊ីហ្វិក (អេសអ៊ីហ្សេក) អ៊ីនវេសមេន ខូ អិលធីឌី** ៤២៥៧

១០-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៤៨៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន ហាវេស ដ្រាយ ហ្វ្រ៊ូត** ៤២៥៩

# ព្រះរាជក្រម

នស/រកម/០៦០៩/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអគ្គទេសាភិបាលធនា-គារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីភតិសន្យាហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩ នាសម័យប្រជុំ រដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបាន យល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៩ នាសម័យប្រជុំវិសាមញ្ញ លើកទី១ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# ភតិសន្យាហិរញ្ញវត្ថុ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់សិទ្ធិ និងកាតព្វកិច្ចដល់ភាគីពាក់ព័ន្ធនឹងប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ និងដាក់ចេញនូវវិធានការ ដើម្បីការពារសិទ្ធិទាំងនោះ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណងអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងសហគ្រាស ដើម្បីបង្កលក្ខណៈធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុដោយស្មើភាព សុវត្ថិភាព ប្រសិទ្ធភាព និងផលិតភាព ស្របតាមការវិវត្តនៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាព គ្របដណ្តប់លើភតិសន្យាហិរញ្ញវត្ថុនៃចលនវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ ។

**មាត្រា ៤.-**

ពាក្យបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ភតិបតី** :សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលផ្ទេរសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុទៅឱ្យភតិកៈ ។

- **ភតិកៈ** :សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុពីភតិបតី ។

- **ចលនវត្ថុ** : សំដៅដល់ទ្រព្យសម្បត្តិ គ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែដី និងអគារ ។

- **រយៈពេល** : សំដៅដល់រយៈពេលដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងរយៈពេលនោះភតិកៈត្រូវបានអនុញ្ញាតឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុដែលបានជួល ។

- **ភតិសន្យា** : សំដៅដល់ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុក្នុងរយៈពេលមួយ ដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬ តាមតម្លៃសមមូល ។ ភតិសន្យា ត្រូវរួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ ។

**-ភតិសន្យាបន្ត** : សំដៅដល់ប្រតិបត្តិការដែលចលនវត្ថុ ត្រូវបានជួលដោយភតិកៈដំបូង ត្រូវបានជួលបន្តឱ្យភាគីផ្សេងទៀត ហើយកិច្ចព្រមព្រៀងភតិសន្យារវាងគូភាគីដំបូង នៅមានសុពលភាពដដែល ។

**-ភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬ ច្រើនជាងដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ :

ក-ភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ

ខ-ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដើម្បីជួលឱ្យភតិកៈ ។

ក៏ប៉ុន្តែ បើមានការជួលបន្តនូវចលនវត្ថុដែលបានជួលពីមុនពីភតិបតីដដែល ការជួលបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល ។

ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់ :

ក-ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបាន ឬ មិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូល ឬ ការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ

ខ-ភតិកៈមាន ឬ ពុំមានជម្រើស ឬ ក្រោយមកទទួលយកជម្រើសថាទិញ ឬ បន្តជួលចលនវត្ថុ មួយរយៈពេលបន្ថែមទៀត ។

**-ការបង់ថ្លៃឈ្នួលជាមុន** : សំដៅដល់ចំនួននៃការបង់ថ្លៃឈ្នួលតាមគ្រាដោយភតិកៈ នៅពេល ឬ មុនពេលចាប់ផ្តើមជួល ។ ការបង់ថ្លៃឈ្នួលជាមុន មិនមែនជាប្រាក់ប្រាតិភោគទេ ។

**-ប្រាក់ប្រាតិភោគ** : សំដៅដល់ចំនួនប្រាក់ដែលត្រូវបានបង់ដោយភតិកៈនិងត្រូវបានកាន់កាប់ដោយភតិបតី ដើម្បីធានាកាតព្វកិច្ច សម្រាប់ឱ្យភតិកៈអនុវត្តតាមភតិសន្យាហិរញ្ញវត្ថុ ដោយពេញលេញ និងទៀងទាត់ ។

**-អ្នកផ្គត់ផ្គង់** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលភតិបតីទទួលចលន-

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

វត្ថុដែលត្រូវជួលឱ្យភតិកៈ ។ លទ្ធកម្មរបស់ភតិបតីអាចប្រព្រឹត្តទៅតាមរយៈការទិញ ការជួល ការប្រគល់សិទ្ធិឱ្យទិញ ឬ ឱ្យជួល រួមទាំងការប្រគល់សិទ្ធិពីភតិកៈផងដែរ ។ នៅក្នុងប្រតិបត្តិការលក់ហើយជួលមកវិញ ភតិកៈអាចជាអ្នកផ្គត់ផ្គង់ ។

**- កិច្ចព្រមព្រៀងផ្គត់ផ្គង់** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុដែលត្រូវជួលឱ្យភតិកៈ ។

**- កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុ ដែលភតិកៈបានជ្រើសរើសពីអ្នកផ្គត់ផ្គង់ ហើយជួលចលនវត្ថុនេះទៅឱ្យភតិកៈ និងអនុញ្ញាតឱ្យភតិកៈបង់ថ្លៃឈ្នួលតាមកាលកំណត់ ។

## ជំពូកទី ២

## កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ

### មាត្រា ៥.-

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយភតិបតីនិងភតិកៈ ហើយត្រូវកំណត់រយៈពេល និងលក្ខខណ្ឌនៃគ្រប់ភាគីទាក់ទងនឹងចលនវត្ថុដែលបានជួល ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមិនចាំបាច់មានការបញ្ជាក់ពីសារការីក៏បានដែរ លើកលែងតែមានច្បាប់ណាមួយតម្រូវ ។

### មាត្រា ៦.-

កិច្ចព្រមព្រៀងមួយដែលពេញលក្ខណៈជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ លុះត្រាតែកិច្ចព្រមព្រៀងនោះ មានចែងចំណុចសំខាន់ៗយ៉ាងតិច ដូចខាងក្រោម :

ក-ការពណ៌នាពីចលនវត្ថុដែលបានជួល

ខ-ចំនួនប្រាក់ ការកំណត់គ្រា និងរយៈពេលនៃការបង់ថ្លៃឈ្នួល

គ-កាលបរិច្ឆេទចាប់ផ្តើមភតិសន្យាហិរញ្ញវត្ថុ និង

ឃ-ហត្ថលេខារបស់ភតិបតី និងភតិកៈ ។

### មាត្រា ៧.-

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចមានចែងអំពីប្រាក់ប្រាតិភោគ ឬ ការបង់ថ្លៃឈ្នួលជាមុន ឬ ទាំងពីរ ។ សម្រាប់ភតិកៈ ប្រាក់ប្រាតិភោគ អាច ឬ មិនអាចទទួលបានទូវ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ចំណូលការប្រាក់ ហើយអាចត្រូវបានបង្វិលឱ្យភតិកៈវិញ ឬ អាចប្រើប្រាស់ ដោយភតិបតី ដូចមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

ក្នុងករណីដែលកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ មិនមានចែងអំពីការប្រើប្រាក់ប្រាតិភោគទេ ប្រាក់ប្រាតិភោគនោះ មិនត្រូវទទួលការប្រាក់ឡើយ និងត្រូវបង្វិលទៅឱ្យភតិកៈវិញ ក្រោយពេលដែលភតិកៈបានបំពេញកាតព្វកិច្ចភតិសន្យាហិរញ្ញវត្ថុបានពេញលេញនិងតាមពេលកំណត់ហើយ ។ ការបង់ថ្លៃឈ្នួលជាមុនមិនត្រូវទទួលបានការប្រាក់ទេ ។ ប្រាក់ប្រាតិភោគ និងការបង់ថ្លៃឈ្នួលជាមុន អាចជាចំនួនប្រាក់ដែលបានព្រមព្រៀងគ្នារវាងភាគីទាំងពីរ ។

## មាត្រា ៨.-

បើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងថា ចលនវត្ថុត្រូវបិទស្លាកសម្គាល់ជាកម្មសិទ្ធិរបស់ភតិបតី ឬ ជាកម្មវត្ថុនៃភតិសន្យាពីភតិបតី ស្លាកសម្គាល់ទាំងនោះមិនត្រូវដកចេញ ឬ ធ្វើឱ្យមើលមិនស្គាល់ ដោយជនណាម្នាក់ ក្រៅពីភតិបតី ឬ អ្នកតំណាងរបស់ភតិបតីនោះឡើយ ។

នៅពេលបានរកឃើញការខូចខាតណាមួយនៃស្លាកសម្គាល់ដែលបណ្តាលឱ្យមើលមិនស្គាល់ ភតិកៈត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅឱ្យភតិបតី ឬ បើពុំដូច្នោះទេ ភតិកៈត្រូវទទួលខុសត្រូវក្នុងកម្រិតដូចដែលភតិកៈបានដកស្លាកសម្គាល់ចេញដោយគ្មានការអនុញ្ញាត ។ ភតិកៈមិនត្រូវទទួលខុសត្រូវក្រោមមាត្រានេះឡើយ ប្រសិនបើភតិបតីខកខានមិនបានផ្លាស់ប្តូរស្លាកសម្គាល់នោះ ក្រោយពីភតិកៈបានជូនដំណឹងទាន់ពេលវេលាឱ្យទៅភតិបតីរួចហើយ ។

## មាត្រា ៩.-

បើភតិបតី និងភតិកៈព្រមព្រៀងគ្នាសងតាមវិធីមិនមែនរូបិយវត្ថុ ដូចជាផលិតផល សេវាកម្ម ការដោះដូរជាវត្ថុ តម្លៃនៃការទូទាត់សង ក្នុងទម្រង់មិនមែនរូបិយវត្ថុនោះ ត្រូវកំណត់តាមថ្លៃទីផ្សារ លើកលែងតែភាគីទាំងពីរ បានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនូវយន្តការណាមួយផ្សេងពីនេះ ។

**មាត្រា ១០.-**

នៅក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈទទួលយកការប្រើប្រាស់ចលនវត្ថុ ក្នុងរយៈពេលយ៉ាងតិចបំផុត ០១ (មួយ) ឆ្នាំ ។ នៅចុងបញ្ចប់នៃកិច្ចព្រមព្រៀងនោះ ភតិកៈអាច ឬ មិនអាចទិញផ្តាច់នូវចលនវត្ថុនោះ ។ ភតិបតីផ្តល់ហិរញ្ញប្បទានសម្រាប់ឱ្យភតិកៈប្រើប្រាស់ចលនវត្ថុ មិនមែនឱ្យធ្វើជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុនោះទេ ។

## ជំពូកទី ៣
## សិទ្ធិ និងកាតព្វកិច្ចរបស់ភតិបតី

**មាត្រា ១១.-**

នៅក្នុង និងក្រោយរយៈពេលនៃភតិសន្យាហិរញ្ញវត្ថុ ភតិបតីនៅតែជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុដែលបានជួល លើកលែងតែកម្មសិទ្ធិត្រូវបានផ្ទេរទៅឱ្យភតិកៈ ឬ ទៅឱ្យភាគីផ្សេងទៀត ។

**មាត្រា ១២.-**

ភតិបតីត្រូវទទួលខុសត្រូវបង់ពន្ធនាំចូល និងកាតព្វកិច្ចសារពើពន្ធផ្សេងៗទៀត តាមច្បាប់កំណត់ និងសោហ៊ុយចុះបញ្ជីលើចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ១៣.-**

ភតិបតីត្រូវទូទាត់សងថ្លៃទិញចលនវត្ថុទៅឱ្យអ្នកផ្គត់ផ្គង់ នៅពេលដែលភតិកៈបានយល់ព្រមទទួលចលនវត្ថុនោះ ដោយគ្មានលក្ខខណ្ឌ ។

**មាត្រា ១៤.-**

ភតិបតីត្រូវធានាយ៉ាងណាឱ្យភតិកៈបានប្រើប្រាស់ និងកាន់កាប់ចលនវត្ថុ ដែលបានជួល ដោយគ្មានការរំខាន នៅក្នុងរយៈពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ ដរាបណាភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ១៥.-**

ភតិបតីមិនទទួលខុសត្រូវចំពោះភតិកៈលើចលនវត្ថុឡើយ លើកលែងតែក្នុងករណីដែលភតិកៈបានទទួលរងការខាតបង់ ដោយសារការធ្វើអន្តរាគមន៍របស់ភតិបតី ក្នុងការជ្រើសរើស ឬ ក្នុងការកំណត់យថាប្រភេទនៃចលនវត្ថុ ។

**មាត្រា ១៦.-**

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីមិនទទួលខុសត្រូវសងការខូចខាត ដែលបង្កដល់តតិយជន ដោយសារចលនវត្ថុដែលខ្លួនបានជួលឡើយ ។

**មាត្រា ១៧.-**

ក្នុងករណីដែលភតិកៈមិនគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិបតីត្រូវមានសិទ្ធិបន្ថែមពីលើសិទ្ធិ ដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដូចតទៅ :

ក-ភតិបតីអាចទាមទារឱ្យភតិកៈបង់ថ្លៃឈ្នួលដែលមិនទាន់បានសង រួមទាំងការប្រាក់ និងការខូចខាត

ខ-ភតិបតីក៏អាចទាមទារឱ្យពន្លឿនការបង់ថ្លៃឈ្នួលនាអនាគតបាន អាចរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងអាចទាមទារយកចលនវត្ថុដែលបានជួលមកវិញ បើមានករណីណាមួយ ដូចខាងក្រោម :

-ភតិកៈមិនបានបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ក្នុងរយៈពេលពីរគ្រាជាបន្តបន្ទាប់

-ភតិកៈបំពានខណាមួយផ្សេងទៀតនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងខកខានមិនបានដោះស្រាយបញ្ហា ក្នុងរយៈពេលដប់ (១០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរពីភតិបតី

-ភតិកៈមានអ្នកធានាដែលគ្មានសាធនភាព ក្ស័យធន ឬ ត្រូវបានរំលាយ ហើយភតិកៈមិនបានរកអ្នកធានាជំនួសណាម្នាក់ ដែលភតិបតីអាចទទួលយកបាន ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ តាមការស្នើសុំឱ្យរកអ្នកធានាជំនួសជាលាយលក្ខណ៍អក្សរពីភតិបតី ។

-ភតិកៈគ្មានសាធនភាព ក្ស័យធន ត្រូវបានរំលាយ ឬ ទទួលមរណភាព ហើយពុំមានអ្នកស្នងបន្ត ។

គ-ទោះបីជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបាន ឬ មិនត្រូវបានរំលាយនៅមុនពេលផុតរយៈពេលក៏ដោយ ភតិបតីអាច :

-ទាមទារយកចលនវត្ថុដែលបានជួលមកកាន់កាប់វិញ ដោយមិនចាំបាច់ប្ដឹងទៅតុលាការ ប្រសិនបើការទាមទារនោះធ្វើឡើង ដោយគ្មានអំពើហិង្សា និង

-ទាមទារសំណងការខូចខាត ដែលភតិបតីត្រូវទទួលបានរាប់ទាំងចំណាយបន្ថែម បណ្ដាលមកពីកំហុសរបស់ភតិកៈផង ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងអំពីវិធីគណនាការខូចខាត ហើយវិធីគណនានេះ អាចអនុវត្តបានដោយភាគីទាំងពីរ លើកលែងតែវិធីគណនានេះ បណ្ដាលឱ្យមានវិការៈធ្ងន់ធ្ងរលើសពីសំណងការខូចខាតដែលភតិបតីអាចនឹងទទួលបាន ប្រសិនបើភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

ឃ-បើចាំបាច់ ភតិបតីអាចដាក់ពាក្យស្នើសុំដីកាសម្រេចពីតុលាការឱ្យភតិកៈប្រគល់ចលនវត្ថុជួលនោះមកភតិបតីវិញ ដោយភ្ជាប់ជាមួយនូវរាល់ឯកសារភស្ដុតាងដែលបង្ហាញថា ភតិកៈមិនបានគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។ ប៉ុន្តែ ភតិបតីនៅតែត្រូវទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលកើតឡើងដល់ភតិកៈ បើនៅពេលក្រោយមកមានភស្ដុតាងបង្ហាញថា ការទាមទារចលនវត្ថុដែលបានជួលមកវិញដោយភតិបតីនោះ ជាការរំលោភលើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

**មាត្រា ១៨.-**

ភតិបតីមានសិទ្ធិតម្រូវឱ្យភតិកៈសងការខាតបង់ បំណុល ការខូចខាត ឬ ផលវិបាកផ្សេងៗណាមួយ ឬ ទាំងអស់ ដែលកើតឡើងពី ឬ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និងការកាន់កាប់របស់ភតិកៈលើចលនវត្ថុដែលបានជួល ។

**មាត្រា ១៩.-**

ភតិបតីអាចទាមទារឱ្យភតិកៈទិញ និងបង់ថ្លៃធានារ៉ាប់រងលើចលនវត្ថុ ដែលបានជួលនៅគ្រប់អំឡុងពេលដែលភតិកៈកាន់កាប់ ឬ គ្រប់គ្រងចលនវត្ថុនោះ ទោះបីជារយៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ បានឈានដល់ទីបញ្ចប់ហើយ ឬ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបានរំលាយមុនពេលក៏ដោយ រហូតដល់ពេលដែលចលនវត្ថុនោះ ត្រូវបានប្រគល់ឱ្យភតិបតីកាន់កាប់ និងគ្រប់គ្រងវិញ ។

ប្រសិនបើភតិកៈត្រូវទិញ និងបង់ថ្លៃជានារ៉ាប់រងហើយបែរជាខកខានទៅវិញ ភតិបតីមានសិទ្ធិទិញ តែមិនមានភារកិច្ចត្រូវទិញធានារ៉ាប់រងនេះទេ ហើយភតិកៈត្រូវសងរាល់ការចំណាយទៅឱ្យភតិបតីវិញភ្លាម ប្រសិនបើភតិបតីបានចំណាយរួចហើយ ។

**មាត្រា ២០.-**

ចលនវត្ថុដែលបានជួល មិនមែនជាចំណែកនៃទ្រព្យសម្បត្តិរបស់ភតិកៈទេ ក្នុងន័យនេះ នៅពេលដែលភតិកៈក្ស័យធន ម្ចាស់បំណុលទាំងឡាយរបស់ភតិកៈរួមទាំងម្ចាស់បំណុលដែលបានទទួលសិទ្ធិរឹបអូសទ្រព្យសម្បត្តិភតិកៈ តាមសេចក្តីសម្រេចរបស់តុលាការផង គ្មានសិទ្ធិទាមទារយកចលនវត្ថុដែលបានជួលនោះទេ ។

**មាត្រា ២១.-**

ភតិបតីអាចចាត់ចែង ផ្ទេរ ឬ ម្យ៉ាងទៀតបែងចែកសិទ្ធិទាំងអស់ ឬ សិទ្ធិណាមួយរបស់ខ្លួនលើចលនវត្ថុដែលបានជួល ឬ តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ទៅឱ្យភាគីណាមួយ ដោយមិនចាំបាច់មានការយល់ព្រមពីភតិកៈ ។ ការផ្ទេរបែបនេះ មិនត្រូវធ្វើឱ្យភតិបតីរួចផុតពីកាតព្វកិច្ចណាមួយ ឬ ផ្លាស់ប្តូរភាពដើមនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុទេ ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈយល់ព្រមមិនទាមទារកាត់កងការពារ ឬ ទាមទារប្រឆាំងនឹងអ្នកដែលត្រូវបានប្រគល់សិទ្ធិ ឬ អនុប្បទានិករបស់ភតិបតីឡើយ ។

**មាត្រា ២២.-**

ក្នុងករណី ភតិបតីក្ស័យធន ឥណទាយករបស់ភតិបតី និងភាគីពាក់ព័ន្ធផ្សេងទៀតមិនមានសិទ្ធិច្រើនជាងសិទ្ធិដែលភតិបតីមាន តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនោះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ksl

11/176

## ជំពូកទី ៤

## សិទ្ធិ និងកាតព្វកិច្ចរបស់ភតិកៈ

**មាត្រា ២៣.-**

ភតិកៈមានកាតព្វកិច្ចយល់ព្រមទទួលចលនវត្ថុដែលបានជួល បើចលនវត្ថុនោះ ត្រូវបានប្រគល់ទាន់ពេលវេលាកំណត់ និងត្រឹមត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ។ បើចលនវត្ថុដែលបានជួលមិនត្រូវបានប្រគល់ ឬ ប្រគល់យឺតពេល ឬ មិនត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេនោះ នៅពេលយល់ព្រម ឬ មុនពេលយល់ព្រម ប៉ុន្តែពុំមែនក្រោយពេលយល់ព្រមទទួលនោះទេ ភតិកៈមានសិទ្ធិបដិសេធចលនវត្ថុនោះ ហើយទាមទារភ្លាមឱ្យអ្នកផ្គត់ផ្គង់ជួសជុលវិការៈនោះ ឬ រំលាយភតិសន្យាហិរញ្ញវត្ថុ ប៉ុន្តែគ្មានសិទ្ធិរំលាយ ដកហូត ឬ កែប្រែកិច្ចព្រមព្រៀងផ្គត់ផ្គង់ ដោយពុំមានការយល់ព្រមពីភតិបតីឡើយ ។

ភតិបតីមានសិទ្ធិឱ្យអ្នកផ្គត់ផ្គង់ប្រគល់ចលនវត្ថុ ស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ តែមិនមានកាតព្វកិច្ចទទួលខុសត្រូវលើការខូចខាត ដោយសារការខកខានរបស់អ្នកផ្គត់ផ្គង់ឡើយ ។

**មាត្រា ២៤.-**

ការយល់ព្រមទទួលចលនវត្ថុ អាចជាឯកសារឬអាចតាមរយៈមធ្យោបាយផ្សេងៗទៀត ដូចខាងក្រោម:

ក-ក្រោយពេលដែលភតិកៈបានពិនិត្យចលនវត្ថុ ដែលត្រូវជួលនោះរួចហើយ ហើយបានបញ្ជាក់ថា អាចទទួលយកបាន ទោះបីជាចលនវត្ថុនោះស្រប ឬ មិនស្រប តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ក៏ដោយ

ខ-ភតិកៈមិនបានជូនដំណឹងទាន់ពេលវេលាដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ ពីភាពមិនស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទៅភតិបតី និងអ្នកផ្គត់ផ្គង់ ដើម្បីឱ្យអ្នកផ្គត់ផ្គង់ ឬ ភតិបតីអាចដោះស្រាយទាន់ពេលវេលា ក្រោយពេលបានទទួលដំណឹងនោះ៖

គ-កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈត្រូវបានចាត់ទុកថា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

12/15

បានយល់ព្រមទទួលចលនវត្ថុ លើកលែងតែភតិបតីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធរបស់ភតិក: ដែលមានរាយលម្អិតពីមូលហេតុច្បាស់លាស់ ក្នុងរយ:ពេលកំណត់៨ប់ (១០) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីភតិក:បានទទួលចលនវត្ថុនោះ ។

**មាត្រា ២៥.-**

តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិក:មានកាតព្វកិច្ចបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងដោយមិនអាចបដិសេធបាន នៅពេលដែលភតិក: បានយល់ព្រមទទួលចលន-វត្ថុជាផ្លូវការហើយ ។

**មាត្រា ២៦.-**

ភតិក: ត្រូវប្រើប្រាស់ចលនវត្ថុឱ្យ បានត្រឹមត្រូវ តាមមុខសញ្ញាប្រើប្រាស់ស្របតាមច្បាប់វិធាន និងបទបញ្ញាជាធរមាន និងតាមលក្ខណ:បច្ចេកទេស ។ ភតិក:ក៏ត្រូវចំណាយលើការថែទាំ និងជួសជុលចលនវត្ថុឱ្យនៅល្អ និងអាចប្រើប្រាស់បាន លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ២៧.-**

នៅដំណាក់កាលផុតរយ:ពេល ឬ នៅពេលរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងក្នុងករណីមិនបានទិញ ឬ មិនបានជួលបន្តទេនោះ ភតិក:ត្រូវប្រគល់ចលនវត្ថុដែលបានជួលទៅឱ្យភតិបតីវិញ ដោយរក្សាលក្ខណ:ដូចដើម លើកលែងតែការសឹករេចរឹលធម្មតា ។

**មាត្រា ២៨.-**

ភតិក: ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ចលនវត្ថុ ដែលបានជួល ចាប់ពីពេលទទួលរហូតដល់ពេលប្រគល់ចលនវត្ថុទៅភតិបតីវិញ ។

**មាត្រា ២៩.-**

ភតិក:មិនត្រូវដាក់ជាហ៊ីប៉ូតែក ដាក់បញ្ចាំ ទាមទារឱ្យឃាត់ទុក ចលនវត្ថុដែលបានជួល ឬធ្វើឱ្យមានបន្ទុកផ្សេងទៀតទៅលើចលនវត្ថុដែលបានជួលឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Kdl

13/17

**មាត្រា ៣០.-**

ភតិកៈ មានកាតព្វកិច្ចផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរទៅភតិបតី អំពីទីតាំងបច្ចុប្បន្ន និងការប្តូរទៅទីតាំងថ្មីនៃចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ៣១.-**

កាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់ តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ក៏ត្រូវពាក់ព័ន្ធជាមួយភតិកៈផងដែរ ប្រៀបដូចជាភតិកៈជាភាគីមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ ហើយចលនវត្ថុដែលបានជួល ហាក់ដូចជាត្រូវបានផ្គត់ផ្គង់ផ្ទាល់ទៅឱ្យភតិកៈ ។ ប៉ុន្តែអ្នកផ្គត់ផ្គង់មិនទទួលខុសត្រូវលើវិការៈមួយចំពោះភតិកៈផង និងភតិបតីផងនោះទេ ។

សិទ្ធិរបស់ភតិកៈ នៅក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ដែលភតិកៈបានយល់ព្រម ហើយមិនត្រូវបានប៉ះពាល់ ដោយសារតែការកែប្រែលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេ លើកលែងតែភតិកៈបានយល់ព្រមលើការកែប្រែនោះ ។

**មាត្រា ៣២.-**

ភតិកៈមិនត្រូវជួលបន្ត ចាត់ចែង ឬ ផ្ទេរសិទ្ធិកាន់កាប់ ឬ ប្រើប្រាស់ចលនវត្ថុ ដែលបានជួល ឬ សិទ្ធិណាមួយផ្សេងទៀត ក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី និងមិនត្រូវចំណុះសិទ្ធិរបស់តតិយភាគីឡើយ ។ ការជួលបន្ត ការចាត់ចែង ឬ ការផ្ទេរ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី ត្រូវចាត់ទុកជាមោឃៈ និងត្រូវបានចាត់ទុកថា ល្មើសច្បាប់នេះ និងច្បាប់ផ្សេងទៀត ។

## ជំពូកទី ៥

## អាជ្ញាធរអាណាព្យាបាល និងអំណាចចេញបទបញ្ជា

**មាត្រា ៣៣.-**

ធនាគារជាតិនៃកម្ពុជា បំពេញតួនាទីជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថាន ភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងតួនាទីនេះ ធនាគារជាតិនៃកម្ពុជា :

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

14/Kh

១-ចេញ ល្យូវ ឬ ដកហូតអាជ្ញាបណ្ណធ្វើប្រតិបត្តិការ ភតិសន្យាហិរញ្ញវត្ថុ និង កំណត់នីតិវិធីនិងបែបបទនានាអំពីការចេញអាជ្ញាបណ្ណនេះ ។

២-ចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់នេះ ដែលអនុញ្ញាតឱ្យកំណត់ច្បាស់ជាអាទិ៍នូវ :

ក-កម្រិតដើមទុនអប្បបរមា

ខ-អនុបាតប្រុងប្រយ័ត្នផ្សេងៗ

គ-ចំណាត់ថ្នាក់ប្រភេទឥណទាន និងការធ្វើសំវិធានធន

ឃ-ប្រព័ន្ធគណនេយ្យ និងបទដ្ឋានដែលពាក់ព័ន្ធ ។

៣-ត្រួតពិនិត្យ តាមវិធីពិនិត្យផ្ទៀងផ្ទាត់ ជាអចិន្ត្រៃយ៍លើឯកសារ និងតាមវិធីត្រួតពិនិត្យតាមកាលវេលាចាំបាច់ ដល់ទីកន្លែងនៃគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ។

៤-អាចសម្រេចដាក់ទណ្ឌកម្មខាងវិន័យ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៥ នៃច្បាប់នេះ ។

**មាត្រា ៣៤.-**

ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ អាចអនុវត្តបានដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណប្រកបមុខរបរធនាគារពីធនាគារជាតិនៃកម្ពុជា ។

ប្រតិបត្តិការទាំងនេះក៏អាចអនុវត្តបានផងដែរ ដោយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើង ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ត្រូវសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការផ្សេងទៀតរបស់ធនាគារ ក្រៅពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៦

## ទណ្ឌកម្ម

**មាត្រា ៣៥.-**

ប្រសិនបើគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬ នៃបទបញ្ជាពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន ឬ មិនបានធ្វើតាមការដាស់តឿន ឬ មិនបានធ្វើតាមអធិបញ្ជា អាជ្ញាធរអាណាព្យាបាល អាចដាក់ទណ្ឌកម្មខាងវិន័យណាមួយដូចខាងក្រោមនេះ :

-ព្រមាន

-ស្តីបន្ទោស

-ហាមធ្វើប្រតិបត្តិការមួយចំនួន និងកំណត់ព្រំដែនសកម្មភាព

-ព្យួរមុខងារបណ្តោះអាសន្ន ចំពោះអ្នកដឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-តម្រូវឱ្យលាឈប់ពីការងារជាស្វ័យប្រវត្តិចំពោះអ្នកដឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-ដាក់ឱ្យស្ថិតនៅក្រោមការអភិបាលបណ្តោះអាសន្ន ជាបន្តបន្ទាប់

-ដកហូតអាជ្ញាបណ្ណជាស្ថាពរ និងការដាក់ឱ្យជម្រះបញ្ជីជាបន្ទាន់ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៦.-**

គ្រឹះស្ថានណាដែលកំពុងធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដោយគ្មាននីតិសម្បទា ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណ ទៅអាជ្ញាធរអាណាព្យាបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។



## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៨.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៩០៦.០១០ **នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ**

លេខ : ៦១៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

17/17

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៦០៧

## ស្តីពី

## ការរៀបចំ និង ការប្រព្រឹត្តទៅ
## នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## យើង

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ.នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា ៣ មាត្រា ៤ មាត្រា៦ មាត្រា ៨ មាត្រា ៩ និងមាត្រា១៣ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣០៨/៣១១ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា២ថ្មី និងមាត្រា១៣ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

### ជំពូកទី១

### អំពីការកំណត់សមាសភាព តួនាទី និងរចនាសម្ព័ន្ធរបស់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**មាត្រា១ .-**

ត្រូវបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ( អក្សរកាត់ អ.ជ.ប.គ.ញ.) ដែលមានសមាសភាព ដូចខាងក្រោម ÷

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី ០១ រូប | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សមាជិក
- រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- រដ្ឋមន្ត្រីក្រសួងពត៌មាន សមាជិក
- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី សមាជិក
- រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក
- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សមាជិក
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សមាជិក
- រដ្ឋមន្ត្រីក្រសួងសាធារណៈការ និង ដឹកជញ្ជូន សមាជិក
- ទេសាភិបាលធនាគារជាតិនៃកម្ពុជា សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- អគ្គលេខាធិការ នៃ អ.ជ.ប.គ.ញ. សមាជិក និង ជាលេខាធិការ

ក្នុងករណីចាំបាច់ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អាចស្នើសុំតែងតាំងឥស្សរៈជន ០១ រូប ជាអនុប្រធាន មានឋានៈស្មើរដ្ឋមន្ត្រី។

**មាត្រា២ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តបទប្បញ្ញត្តិអនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២ អនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និង សារធាតុដែលធ្វើឱ្យប៉ះពាល់សរសៃប្រសាទ ឆ្នាំ១៩៨៨ និង បទដ្ឋានគតិយុត្តិអន្តរជាតិនានាស្តីពីគ្រឿងញៀន



- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដើម្បីទប់ស្កាត់ ការដាំដុះ ការផលិត ការចរាចរ ការជួញដូរគ្រឿងញៀន និង សារធាតុគីមីផ្សំគ្រឿងញៀន
- អប់រំ ផ្សព្វផ្សាយ លើកកំពស់ការយល់ដឹងអំពីបញ្ហាគ្រឿងញៀនដល់សាធារណៈជន ដើម្បីកាត់បន្ថយ និង ឈានទៅលុបបំបាត់តំរូវការគ្រឿងញៀន ការផ្គត់ផ្គង់គ្រឿងញៀន និងការប្រើបំពានគ្រឿងញៀន
- គ្រប់គ្រង និងបង្កើតមជ្ឈមណ្ឌលអប់រំ ព្យាបាល និងស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកជាសះស្បើយពីគ្រឿងញៀនចូលក្នុងសហគមន៍ និងគ្រួសារវិញ
- ទំនាក់ទំនងសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានាដើម្បីស្វែងរកមូលនិធិសម្រាប់សកម្មភាពបង្ការទប់ស្កាត់បទល្មើសគ្រឿងញៀន
- ដឹកនាំ សម្របសម្រួល និង អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំតាក់តែងអត្ថបទច្បាប់ និងបទដ្ឋានគតិយុត្ត ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- លើកទឹកចិត្តដល់អ្នកផ្តួចផ្តើមគំនិតក្នុងការប្រយុទ្ធប្រឆាំងនឹងជំនួញគ្រឿងញៀន សារធាតុសំរាប់ផ្សំគ្រឿងញៀន និងការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់
- អាជ្ញាធរជាតិ ត្រូវធានាអនុវត្តកាតព្វកិច្ចដែលមានចែងក្នុង អនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀន ព្រមទាំងដាក់ឱ្យអនុវត្តនូវយន្តការជាតិនិងអន្តរជាតិ ដើម្បីធានានិរន្តរភាពសំរាប់ការត្រួតពិនិត្យគ្រឿងញៀន
- អនុវត្តការកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

**មាត្រា៣ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ និងមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជាខ្សែបណ្តោយ ។

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិស្នើសុំបង្កើតគណៈកម្មាធិការសំរាប់បំពេញមុខងារតាមជំនាញ ។ ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៤ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានត្រាប្រើប្រាស់ជាផ្លូវការ ។

**មាត្រា៥ .-**

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិស្នើសុំមន្ត្រីពីក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ ។

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិស្នើសុំមន្ត្រីមានក្របខ័ណ្ឌពីស្ថាប័ននានាមកបំរើការងារនៅអគ្គលេខាធិការដ្ឋាន នៃអ.ជ.ប.គ.ញ បើយល់ឃើញថាចាំបាច់ ។

**មាត្រា៦ .-**

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិស្នើសុំតែងតាំង ឬ តំលើងឋានន្តរស័ក្តិ ឬដាក់ពិន័យមន្ត្រីរាជការក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ បន្ទាប់ពីមានការយល់ព្រមពីប្រធានស្ថាប័នដែលគ្រប់គ្រងមន្ត្រីនោះ ។

**មាត្រា៧ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រជុំយ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ ។

គ្រប់ពេលប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រសិនបើសមាជិកណាម្នាក់មានធុរៈមិនអាចចូលរួមប្រជុំបាន សមាជិកនោះត្រូវចាត់តាំងតំណាងមួយរូបដែលមានសិទ្ធិសំរេចមកចូលរួមជំនួស ។

ក្នុងករណីចាំបាច់ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អាចអញ្ជើញប្រធានស្ថាប័ន និងបុគ្គលផ្សេងទៀត ដែលពាក់ព័ន្ធនឹងរបៀបវារៈចូលរួមប្រជុំ ។

## ជំពូកទី២
## អំពីអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**មាត្រា៨ .-**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃក្រសួងមហាផ្ទៃ ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

អគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ ត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប និង មានអគ្គលេខាធិការរងជាជំនួយ ។



**មាត្រា៩ .-**

អគ្គលេខាធិការ និង អគ្គលេខាធិការរង នៃអ.ជ.ប.គ.ញ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និង អនុក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី និង តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៣
## អំពីធនធាន និងថវិកា

**មាត្រា១០ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានថវិកា ដើម្បីអនុវត្តការងាររបស់ខ្លួន ។ ធនធាននិងថវិកានេះបានមកពី÷

- ថវិកា ដែលជាកញ្ចប់ដោយឡែក ក្នុងកញ្ចប់ថវិការបស់ក្រសួងមហាផ្ទៃ
- ប្រាក់ជំនួយ អំណោយ ឬវិភាគទានដែលផ្តល់ជូនអាជ្ញាធរជាតិ ដោយរដ្ឋាភិបាលបរទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និង សប្បុរសជន សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ទ្រព្យ និង វត្ថុដទៃទៀត ដែលបានមកដោយការអនុវត្តន៍សេចក្តីសម្រេចរឹបអូសរបស់តុលាការពីជំនួញគ្រឿងញៀនខុសច្បាប់ដែលបានបញ្ចូលទៅក្នុងបេឡាមូលនិធិនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**មាត្រា១១ .-**

ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនត្រូវបានទទួលការតែងតាំងអោយអនុវត្តសិទ្ធិអាណាប័កជំនួស "អាណាប័កផ្ទេរសិទ្ធិ" តាមការសម្រេចចិត្តរបស់អាណាប័កដើមខ្សែ ។

**មាត្រា១២ .-**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុម័តការប្រើប្រាស់មូលនិធិរបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ និងត្រួតពិនិត្យការប្រើប្រាស់ថវិការបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ព្រមទាំងមានសិទ្ធិចាត់ចែងថវិកា និងទ្រព្យសម្បត្តិដែលបានបញ្ចូលទៅក្នុងបេឡាមូលនិធិដូចមានចែងក្នុងមាត្រា ១០ នៃព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

ត្រូវបានទុកជានិរាករណ៍ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ និង ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣១១ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ ។

**មាត្រា១៤ .-**

ការអនុវត្តន៍ភ្លាមនៃព្រះរាជក្រឹត្យនេះ ពុំមានអានុភាពលើសុពលភាពនៃបទដ្ឋានគតិយុត្តិទាំងឡាយដែលបាននិងកំពុងបំពេញដោយអនុលោមទៅតាមព្រះរាជក្រឹត្យដែលត្រូវបាននិរាករណ៍តាមមាត្រា ១៣ នៃព្រះរាជក្រឹត្យនេះរហូតដល់មានបទដ្ឋានគតិយុត្តិថ្មីមកជំនួស ។

**មាត្រា១៥ .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**មាត្រា១៦ .-**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៩*

*នស/រកត/០៥០៩/៦១៤*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៥៥៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៦០៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

## ស្រេចសម្រេច

**មាត្រា ១.-**

ត្រូវបានផ្ទេរបញ្ចូលលោក គង់ ទិមាន ទៅក្នុងឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣៩/លេ.០៥០៥.៦២៥*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩*

លេខ : ៥៧០ . ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិន្តេន

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៥០៩/៦១១

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម ឆោម ម៉ុនខន | មានឋានៈស្មើ | រដ្ឋលេខាធិការ | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២-ឯកឧត្តម សួន ឈាងលី | មានឋានៈស្មើ | រដ្ឋលេខាធិការ | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣-ឯកឧត្តម អ៊ុច សុខុន | មានឋានៈស្មើ | អនុរដ្ឋលេខាធិការ | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤-ឯកឧត្តម ឆួន វណ្ណឌី | មានឋានៈស្មើ | អគ្គនាយក | |

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ : ៥៤៩ ច.ល

៣រល.០៩០៥.៦១៧

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០០៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩*

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

នស/រកត/០៦០៩/៦១២

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ២ :** តម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| **ទីស្តីការគណៈរដ្ឋមន្ត្រី** | | | |
| ១ | ឯកឧត្តម **ឈៀង យ៉ាំណារ៉ា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| [illegible] | ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| [illegible] | ឯកឧត្តម **ជា វ៉ាន់ដេត** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | |
| [illegible] | ឯកឧត្តម **វង្សី វិស្សុត** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

| | | | |
|---|---|---|---|
| ៥ | ឯកឧត្តម ជុំ ទិជិត្ត | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣ |

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៧.០៩០៦.៦១៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៩

លេខ : ៥៦៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ានិត

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦២៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា"
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា"
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា"

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា មួយ.-**

ត្រូវបានកែសម្រួលមាត្រា ៤ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ "អប្សរា" ដូចតទៅ÷

**មាត្រា ៤ថ្មី(ពីរ).-**

អាជ្ញាធរ "អប្សរា" ត្រូវស្ថិតនៅក្រោមការដឹកនាំនៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ "អប្សរា" និងមានមុខតំណែងជាប្រធានអាជ្ញាធរ "អប្សរា"។

ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ "អប្សរា" មានសមាសភាពដូចតទៅ÷

- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
- អភិបាលខេត្តសៀមរាប អនុប្រធាន
- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- អគ្គនាយកអាជ្ញាធរ "អប្សរា" សមាជិក។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យ។

អាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាលមានរយៈពេល ០៣(បី)ឆ្នាំ។

**មាត្រា ពីរ.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៩*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត/០៦០៩/៦១៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៥៤៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦១៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឥស្សរជនចំនួន ០៧ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

- ឯកឧត្តម **ឡាញ់ កៅ** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឯកឧត្តម **យឹម សាញ់** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឯកឧត្តម **មែក ប៊ុន្នី** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឯកឧត្តម **ហ៊ុល ណារី** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឯកឧត្តម **ម៉ាន់ ស៊ីថណ្ណា** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឯកឧត្តម **ធេព ចំរើន** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឯកឧត្តម **ម៉ក់ រ៉ា** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៩០៦.៦២០

លេខ : ៥៦០ ច.ល

**ដើម្បីចម្លងចែក**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៩*

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ណៅ ធួក

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៧.០៩០៦.៦២២

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៩

លេខ : ៥៦៤.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៨៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៩ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងផែនការ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ៤០៥ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកអូរជ្រៅ នៃខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកអូរជ្រៅ នៃខេត្តបន្ទាយមានជ័យ អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **ឡៃក ចំរើន** ជាប្រធានក្រុមប្រឹក្សាស្រុក

២- លោក ស សុខុន ជាសមាជិកក្រុមប្រឹក្សាស្រុក
៣- លោក ឈិត សុច ជាសមាជិកក្រុមប្រឹក្សាស្រុក
៤- លោក អ៊ូ សុខអ៊ាន ជាសមាជិកក្រុមប្រឹក្សាស្រុក
៥- លោកស្រី សំ សុផាណេត ជាសមាជិកក្រុមប្រឹក្សាស្រុក
៦- លោក យក់ ដួង ជាសមាជិកក្រុមប្រឹក្សាស្រុក
៧- លោក ស៊ីន្ន សាមិត្ត ជាសមាជិកក្រុមប្រឹក្សាស្រុក
៨- លោក ម៉ៅ ចុល ជាសមាជិកក្រុមប្រឹក្សាស្រុក
៩- លោក ឡឹក សំឡាន ជាសមាជិកក្រុមប្រឹក្សាស្រុក
១០- លោក ហួត សុភាព ជាសមាជិកក្រុមប្រឹក្សាស្រុក
១១- លោក សៅ ពលភ្ជួណ៍ ជាសមាជិកក្រុមប្រឹក្សាស្រុក
១២- លោក គង់ វណ្ណា ជាសមាជិកក្រុមប្រឹក្សាស្រុក
១៣- លោក ណាំ តុង ជាសមាជិកក្រុមប្រឹក្សាស្រុក
១៤- លោក យុត សុរដ្ឋ ជាសមាជិកក្រុមប្រឹក្សាស្រុក
១៥- លោក ឆាត់ សារឿន ជាសមាជិកក្រុមប្រឹក្សាស្រុក ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកអូរជ្រៅ នៃខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៩*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុងសិរីសោភ័ណ នៃខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុងសិរីសោភ័ណ នៃខេត្តបន្ទាយមានជ័យ អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **គី ឈួន** ជាប្រធានក្រុមប្រឹក្សាក្រុង

២- លោក **ឈុំ រួម** ជាសមាជិកក្រុមប្រឹក្សាក្រុង

៣- លោក **ឈើយ តាំងគួយ** ជាសមាជិកក្រុមប្រឹក្សាក្រុង

៤- លោកស្រី **ស៊ីន ឡុត** ជាសមាជិកក្រុមប្រឹក្សាក្រុង

៥- លោក **ទ្រាក់ សុផល** ជាសមាជិកក្រុមប្រឹក្សាក្រុង

៦- លោក **លាវ នូ** ជាសមាជិកក្រុមប្រឹក្សាក្រុង

៧- លោក **ជុន មូល** ជាសមាជិកក្រុមប្រឹក្សាក្រុង

៨- លោក **ហែម ផុន** ជាសមាជិកក្រុមប្រឹក្សាក្រុង

៩- លោក **លឹម តិចឆេង** ជាសមាជិកក្រុមប្រឹក្សាក្រុង

១០- លោក **ចាន់ សាម៉ាត** ជាសមាជិកក្រុមប្រឹក្សាក្រុង

១១- លោក **ជាម សុខ** ជាសមាជិកក្រុមប្រឹក្សាក្រុង

១២- លោក **ទ័ន ទិបឿន** ជាសមាជិកក្រុមប្រឹក្សាក្រុង

១៣- លោក **គង់ ថន** ជាសមាជិកក្រុមប្រឹក្សាក្រុង

១៤- លោកស្រី **អ៊ុំម ណារី** ជាសមាជិកក្រុមប្រឹក្សាក្រុង

១៥- លោក **ឃ្លាំង ម៉ិនឡាយ** ជាសមាជិកក្រុមប្រឹក្សាក្រុង ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុងសិរីសោភ័ណ នៃខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តតាម រដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

---

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០០៩*

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨២៣.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកស្វាយចេក នៃខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកស្វាយចេក នៃខេត្តបន្ទាយមានជ័យ អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **ស៊ឹម ឆុន** ជាប្រធានក្រុមប្រឹក្សាស្រុក

២- លោក ម៉ៅ ហ៊ី ជាសមាជិកក្រុមប្រឹក្សាស្រុក
៣- លោក យ៉ង់ ខួនស្រ៊ាង ជាសមាជិកក្រុមប្រឹក្សាស្រុក
៤- លោក ស៊ិម ភីន ជាសមាជិកក្រុមប្រឹក្សាស្រុក
៥- លោក មុខ សារ៉ាត់ ជាសមាជិកក្រុមប្រឹក្សាស្រុក
៦- លោក លាង ផា ជាសមាជិកក្រុមប្រឹក្សាស្រុក
៧- លោក ទ៉ៅល គត់ ជាសមាជិកក្រុមប្រឹក្សាស្រុក
៨- លោក មុំ ម៉ៅ ជាសមាជិកក្រុមប្រឹក្សាស្រុក
៩- លោក ហ៊ុន ស្មៀន ជាសមាជិកក្រុមប្រឹក្សាស្រុក
១០- លោក ពិន សារឿន ជាសមាជិកក្រុមប្រឹក្សាស្រុក
១១- លោកស្រី ណំ សោម ជាសមាជិកក្រុមប្រឹក្សាស្រុក
១២- លោក មួង ចាន់រ៉ុង ជាសមាជិកក្រុមប្រឹក្សាស្រុក
១៣- លោក បឿន សារឿប ជាសមាជិកក្រុមប្រឹក្សាស្រុក
១៤- លោក សាយ ហាន់ ជាសមាជិកក្រុមប្រឹក្សាស្រុក
១៥- លោក យ៉ោន ផល់ ជាសមាជិកក្រុមប្រឹក្សាស្រុក ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកស្វាយចេក នៃខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៥
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកថ្មពួក នៃខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកថ្មពួក នៃខេត្តបន្ទាយមានជ័យ អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **យស់ យ៉ន** ជាប្រធានក្រុមប្រឹក្សាស្រុក

២- លោក **មិន ឈយ់** ជាសមាជិកក្រុមប្រឹក្សាស្រុក

៣- លោក **ចូច នាច** ជាសមាជិកក្រុមប្រឹក្សាស្រុក

៤- លោក **ម៉ើយ មួន** ជាសមាជិកក្រុមប្រឹក្សាស្រុក

៥- លោក **ណាល់ ទេវា** ជាសមាជិកក្រុមប្រឹក្សាស្រុក

៦- លោកស្រី **ឈឿម សុខា** ជាសមាជិកក្រុមប្រឹក្សាស្រុក

៧- លោក **ឯក សទ្វាត** ជាសមាជិកក្រុមប្រឹក្សាស្រុក

៨- លោក **ចាន់ ថាន** ជាសមាជិកក្រុមប្រឹក្សាស្រុក

៩- លោក **ជា ឈាន** ជាសមាជិកក្រុមប្រឹក្សាស្រុក

១០- លោក **រ៉ី រឿយ** ជាសមាជិកក្រុមប្រឹក្សាស្រុក

១១- លោក **សា នឿត** ជាសមាជិកក្រុមប្រឹក្សាស្រុក

១២- លោក **ហៀង ឡាំ** ជាសមាជិកក្រុមប្រឹក្សាស្រុក

១៣- លោក **គាន តិក** ជាសមាជិកក្រុមប្រឹក្សាស្រុក ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកថ្មពួក នៃខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:៤០៩.អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកភ្នំស្រុក នៃខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកភ្នំស្រុក នៃខេត្តបន្ទាយមានជ័យ អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **ម៉ា សារ៉េម** ជាប្រធានក្រុមប្រឹក្សាស្រុក

២- លោក **ឈុត ចាន់សេរី** ជាសមាជិកក្រុមប្រឹក្សាស្រុក
៣- លោក **ឃុត ម៉ុនឆួង** ជាសមាជិកក្រុមប្រឹក្សាស្រុក
៤- លោក **កែវ រ៉ុក** ជាសមាជិកក្រុមប្រឹក្សាស្រុក
៥- លោក **ចៅ ម៉ូវឆុំ** ជាសមាជិកក្រុមប្រឹក្សាស្រុក
៦- លោក **ឌី សារុន** ជាសមាជិកក្រុមប្រឹក្សាស្រុក
៧- លោកស្រី **ឈឹម កញ្ញា** ជាសមាជិកក្រុមប្រឹក្សាស្រុក
៨- លោក **ស៊ិញ ឈិញ** ជាសមាជិកក្រុមប្រឹក្សាស្រុក
៩- លោក **ឡាយ គី** ជាសមាជិកក្រុមប្រឹក្សាស្រុក
១០- លោក **កង សាវុន** ជាសមាជិកក្រុមប្រឹក្សាស្រុក
១១- លោក **កឿង សុខ** ជាសមាជិកក្រុមប្រឹក្សាស្រុក
១២- លោក **ឃ្លិញ វណ្ណា** ជាសមាជិកក្រុមប្រឹក្សាស្រុក
១៣- លោក **សួន អ៊ុន** ជាសមាជិកក្រុមប្រឹក្សាស្រុក
១៤- លោក **ព្រំ វិញ** ជាសមាជិកក្រុមប្រឹក្សាស្រុក
១៥- លោក **សំ ឈុំ** ជាសមាជិកក្រុមប្រឹក្សាស្រុក ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកភ្នំស្រុក នៃខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត* *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៣ សរ

សារាចរ

ស្តីពី

ការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣

(ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣)

១. <u>សេចក្តីផ្តើម</u> :

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤នៃរដ្ឋសភា គូសបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី១៥ យ៉ាងច្បាស់ថា : *"រាជរដ្ឋាភិបាលទទួលស្គាល់នូវភាពចាំបាច់នៃការធានាសង្គតិភាព នៃឋានានុក្រម តួនាទី ខ្លឹមសារ និងលំដាប់លំដោយនៃការអនុវត្តរវាង "យុទ្ធសាស្ត្រចតុកោណ" ជាមួយនឹង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ" ក៏ដូចជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ" ព្រមទាំងជាមួយនឹងឯកសារដែលមានលក្ខណៈជា ផែនការគោលនយោបាយ កម្មវិធីវិនិយោគ និង ថវិកាជាតិ"* ។ *ប្រការនេះ តម្រូវឱ្យរាជរដ្ឋាភិបាល ពិនិត្យមើលឡើងវិញនូវសង្គតិភាពនៃអាណត្តិកាលរបស់ "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ" ជាមួយនឹង "កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល" ដែលមាន "យុទ្ធសាស្ត្រចតុកោណ" ជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច"* ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល បានសម្រេចថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផយអជ) ថ្មីមួយ ត្រូវរៀបចំឡើង ដោយធ្វើបច្ចុប្បន្នកម្ម ផយអជ ២០០៦-២០១០ ឱ្យដល់ឆ្នាំ ២០១៣ ដើម្បីឱ្យបានស្របតាមអាណត្តិកាលរបស់ខ្លួន ។

២. <u>ទំហំ និង ទម្រង់</u> របស់ <u>ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣</u> :

- យោងតាមហេតុផលដូចបានគូសបញ្ជាក់ខាងលើ ឯកសារដែលនឹងត្រូវរៀបចំឡើង នឹងក្លាយជា ផយអជ ថ្មីមួយ ដែលនឹងមានឈ្មោះថា <u>ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣</u> ហើយអាណត្តិកាលរបស់ ផយអជ ២០០៦-២០១០ នឹងត្រូវចាត់ទុកថាបានបញ្ចប់ក្នុងឆ្នាំ២០០៨ ។ អាស្រ័យហេតុនេះ ការអនុវត្តតាមនីតិវិធីនានា ដើម្បីទទួលបានការយល់ព្រមពីអំណាចនីតិប្បញ្ញត្តិ គឺជាប្រការចាំបាច់ ។

- ផែនការនោះ នឹងយក **ឆ្នាំ២០០៨** ជាឆ្នាំគោល (**ស្ថានភាព ឬ តួលេខ ជាក់ស្តែង**) ហើយ នឹងបង្ហាញពីវឌ្ឍនភាពនៅក្នុងឆ្នាំ២០០៩ (**ជាបណ្តោះអាសន្ន**) ព្រមទាំង ការប៉ាន់ស្មាន និង ការព្យាករណ៍ សម្រាប់ដំណាក់កាលឆ្នាំ **២០១០-២០១៣** ។
- ឯកសារនោះ នឹងត្រូវរៀបចំឡើង ទៅតាមទម្រង់របស់ "**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២**" ។

## ៣. <u>ខ្លឹមសារ របស់ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣</u> :

ក្នុងលក្ខណៈជាផែនទីចង្អុលផ្លូវ សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា នាពេលអនាគត ខ្លឹមសាររបស់ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ត្រូវផ្តោតលើ :

- គោលដៅជាអាទិភាពរបស់រាជរដ្ឋាភិបាល ដូចបានកំណត់នៅក្នុង **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** ដែលប្រមូលផ្តុំការយកចិត្តទុកដាក់លើ :
  - ➢ ការធានាឱ្យបាននូវចីរភាពសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម សំដៅលើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។
  - ➢ ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុន នៅក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ ។
  - ➢ ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រ ឱ្យបានលើស ១% ក្នុងមួយឆ្នាំ និង ការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ ។
  - ➢ ការធានាបង្កើនវិសាលភាព ប្រសិទ្ធភាព និង គុណភាព នៃសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ហើយទទួលបាននូវការជឿទុកចិត្ត ។
- ការវាយតម្លៃកាលានុវត្តភាព និង បញ្ហាប្រឈម ទាំងឡាយ ដែលកម្ពុជាអាចជួបប្រទះ ដោយផ្អែកលើការប៉ាន់ស្មាននានា ដែលមានលក្ខណៈប្រាកដនិយម នៅក្នុងស្ថានភាពមិននឹងននៃសេដ្ឋកិច្ចសាកលលោក ។
- វិធានការគោលនយោបាយកម្រិត ម៉ាក្រូ អន្តរវិស័យ និង វិស័យ ព្រមទាំង អាទិភាព កម្មវិធី និងសំណើគម្រោង ថ្មីៗ ដែលសំដៅជំរុញ ការកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស ការធ្វើឱ្យសម្រេច **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** ការធានាឱ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការបន្តធានាឱ្យមានកំណើនដែលផ្អែកលើមូលដ្ឋានធំទូលាយ ដោយត្រូវធ្វើការពិនិត្យមើលជាថ្មី លើវឌ្ឍនភាពដែលមានរហូតមកដល់ពេលនេះ និង លើស្ថានភាពក្នុងនិងក្រៅប្រទេស ក្នុងនោះរួមទាំង បណ្តាកត្តាក្រៅប្រទេសដែលប្រែប្រួលមិនអាចដឹងជាមុនបាន (ដូចជា ដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ច វិបត្តិហិរញ្ញវត្ថុ ការប្រែប្រួលថ្លៃទំនិញប្រើប្រាស់ និង ការប្រែប្រួលអាកាសធាតុ នៅលើពិភពលោកទាំងមូល) ។

- ការពិនិត្យកែសម្រួលនិងកំណត់ គោលដៅ និងចំណុចដៅ សំខាន់ៗ ព្រមទាំង ការធ្វើការព្យាករណ៍ថ្មីៗ សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅកម្ពុជា នាដំណាក់កាលខាងមុខ រហូតដល់ឆ្នាំ២០១៣ ។
- ការកំណត់តម្លៃនៃការចំណាយ សម្រាប់ការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ និង វិភាជន៍តាមវិស័យ ដែលសមស្របទៅនឹងអាទិភាព និង គោលដៅតាមវិស័យនីមួយៗ ដែលពាក់ព័ន្ធនឹងគោលដៅរួម ដោយផ្អែកលើធនធានសរុបដែលអាចមាន ។
- ការពង្រឹងយន្តការសម្រាប់ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ វឌ្ឍនភាពនៃការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ តាមរយៈការធ្វើសមាហរណកម្មការងារផែនការ ការងារថវិកា និងការងារគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។

៤. <u>ស្ថាប័នទទួលខុសត្រូវ</u> :

ក. <u>*ក្រសួងផែនការ*</u> :

ក្រសួងផែនការ គឺជា ស្ថាប័នដែលទទួលខុសត្រូវក្នុងការដឹកនាំដំណើរការរៀបចំ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ហើយ ត្រូវ :

- ផ្តល់ការណែនាំផ្នែកបច្ចេកទេស ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អំពីការរៀបចំធាតុចូល និងអំពីដំណើរការរួមនៃការរៀបចំ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ។
- ប្រមែប្រមូលយកធាតុចូលទាំងឡាយ ពីក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ។
- រៀបចំចងក្រង និងកែសម្រួលឯកសារនេះ ដោយផ្អែកលើ ធាតុចូល សំណើ និង អនុសាសន៍ ទាំងឡាយ ដែលទទួលបានពីអ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់ តាមដំណាក់កាលនីមួយៗ នៃដំណើរការរៀបចំឯកសារនេះ ។
- ធ្វើការពិគ្រោះយោបល់ និង សម្របសម្រួល យ៉ាងជិតស្និទ្ធ និងទៀងទាត់ ជាមួយនឹង ស្ថាប័នកណ្តាលបីផ្សេងទៀត (*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*) នៅតាមដំណាក់កាលនីមួយៗ នៃដំណើរការរៀបចំឯកសារនេះ ។
- រាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលកម្ពុជា ពីវឌ្ឍនភាពនៃការអនុវត្តភារៈកិច្ចនេះ តាមដំណាក់កាលនីមួយៗ នៃដំណើរការរៀបចំឯកសារនេះ ។

ខ. <u>*ក្រសួង-ស្ថាប័នពាក់ព័ន្ធ*</u> :

ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវបង្កើតក្រុមការងារមួយ ដែលដឹកនាំដោយមន្ត្រីជាន់ខ្ពស់មួយរូបចាប់ពីថ្នាក់រដ្ឋលេខាធិការឡើងទៅ ដើម្បីអនុវត្តភារៈកិច្ចនេះ ដោយធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងផែនការ ហើយត្រូវជូនដំណឹងមកក្រសួងផែនការ អំពីសមាសភាពនៃក្រុមការងារនេះ ទៅតាមកាលបរិច្ឆេទដូចបានកំណត់ នៅក្នុងឧបសម្ព័ន្ធទី១ នៃសារាចរនេះ ។ ក្រសួង-ស្ថាប័ន ពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាលក៏ត្រូវផ្តល់មកក្រសួងផែនការផងដែរ នូវធាតុចូលដំបូងរបស់ខ្លួន សម្រាប់ការរៀបចំ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដូចបានកំណត់ នៅក្នុងឧបសម្ព័នទី១ នៃសារាចរនេះ ។ ក្នុងន័យនេះ ការណែនាំមួយចំនួន អំពីការរៀបចំធាតុចូលដែលត្រូវផ្តល់ ឱ្យដោយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ នឹងត្រូវបង្ហាញនៅក្នុង ឧបសម្ព័ន្ធទី១ ទី២ និង ទី៣ ។

ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវផ្តល់ឱ្យបានទាន់ពេល នូវធាតុចូលទាំងឡាយដែលមានព័ត៌មានពេញលេញ និង ផ្តល់កិច្ចសហការ ដល់ក្រសួងផែនការ នៅក្នុងការអនុវត្តភារៈកិច្ចនេះ ឱ្យបានសមស្របទៅតាមកម្មវិធីការងារ ដែលបានគ្រោងទុក ។

៥. ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវសហការជាមួយ ក្រសួងផែនការ ក្នុងការរៀបចំ **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ទៅតាមស្មារតីនៃសារាចរនេះ ឱ្យទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែឧសភា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-គ្រប់ក្រសួង-ស្ថាប័ន

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត-រាជធានី

-កាលប្បវត្តិ-ឯកសារ

## ឧបសម្ព័ន្ធទី១

## កម្មវិធីការងារ

### ២០០៩

***មករា*** ការរៀបចំសេចក្តីព្រាង ឯកសារទស្សនទានស្តីពីការរៀបចំ ផយអវ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយ ក្រសួងផែនការ សម្រាប់ការពិភាក្សានិងប្រើប្រាស់ផ្ទៃក្នុងស្ថាប័នកណ្តាលទាំងបួន (ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិ សម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) និង សម្រាប់ធ្វើជាមូលដ្ឋានផ្នែកគោលទស្សនៈ ក្នុងការរៀបចំ សារាចរមួយរបស់ រាជរដ្ឋាភិបាលកម្ពុជា ។

***មីនា-មេសា*** ការពិនិត្យពិចារណានិងការឯកភាពលើសេចក្តីព្រាង ឯកសារទស្សនទាន និង សារាចរស្តីពីការរៀបចំ ផយអវ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយស្ថាប័នកណ្តាលទាំងបួនខាងលើ ។

***ឧសភា-មិថុនា***
- រាជរដ្ឋាភិបាលកម្ពុជា ប្រកាសចេញនូវ សារាចរស្តីពីការរៀបចំ ផយអវ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ។
- ក្រសួងផែនការ ជូនដំណឹង ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ស្តីពីការផ្តល់ធាតុចូល សម្រាប់ការរៀបចំ ផយអវ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ។
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ ផ្ញើជូនក្រសួងផែនការ អំពីសមាសភាពនៃក្រុមការងាររៀបចំ ផយអវ បច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់ខ្លួន មិនឱ្យហួសពី ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ ។
- ការជ្រើសរើសទីប្រឹក្សាអន្តរជាតិមួយរូប ដើម្បីជួយកិច្ចការនេះ ។
- ក្រសួងផែនការរៀបចំសិក្ខាសាលាជាតិមួយ ដើម្បីប្រកាសផ្សព្វផ្សាយ សារាចររបស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ ផយអវ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ។

***១៥ កក្កដា*** ក្រសួង-ស្ថាប័នពាក់ព័ន្ធ ផ្តល់ធាតុចូល មកក្រសួងផែនការ មិនឱ្យហួសពីកាលបរិច្ឆេទនេះ ។

***កក្កដា-តុលា***
- ក្រសួងផែនការ ជួបជាមួយក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ដើម្បីរកធាតុចូលបន្ថែមទៀត និងដើម្បីធ្វើការបញ្ជាក់លើបញ្ហាមួយចំនួនទាក់ទងនឹងធាតុចូលដែលបានទទួល ។
- ក្រសួងផែនការរាយការណ៍ ជូនប្រមុខរាជរដ្ឋាភិបាល ពីវឌ្ឍនភាពនៃការប្រមូលធាតុចូល សម្រាប់ការរៀបចំ ផយអវ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ។
- ក្រសួងផែនការសម្របសម្រួលឱ្យមានកិច្ចប្រជុំ រវាងស្ថាប័នកណ្តាលទាំងបួន (ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) ដើម្បីពិភាក្សានិងផ្តល់ការណែនាំលើការរៀបចំសេចក្តីព្រាងទីមួយ ។

- ក្រសួងផែនការចាប់ផ្តើមដំណើរការរៀបចំសេចក្តីព្រាងទីមួយ ។

**៣០ កញ្ញា** ក្រសួងផែនការសម្របសម្រួលឱ្យមាន កិច្ចប្រជុំរវាងស្ថាប័នកណ្តាលទាំងបួន (ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) ដើម្បីពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងទីមួយ ។

**២៨ តុលា** ក្រសួងផែនការផ្ញើសេចក្តីព្រាងទីមួយទៅជូន ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណែកពាក់ព័ន្ធដទៃទៀត ដើម្បីសុំការផ្តល់អនុសាសន៍ ។

**២០ វិច្ឆិកា** ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណែកពាក់ព័ន្ធដទៃទៀត ផ្តល់អនុសាសន៍ទាំងឡាយ មកក្រសួងផែនការ មិនឱ្យហួសពីកាលបរិច្ឆេទនេះ ។

**១៥ ធ្នូ** ក្រសួងផែនការ ផ្ញើសេចក្តីព្រាងកែសម្រួល ជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ មុនកិច្ចប្រជុំអន្តរក្រសួង ។

## ២០១០

**មករា**
- ក្រសួងផែនការរៀបចំកិច្ចប្រជុំអន្តរក្រសួងមួយ ដើម្បីពិភាក្សាលើសេចក្តីព្រាងកែសម្រួល ។
- ក្រសួងផែនការរាយការណ៍ ជូនប្រមុខរាជរដ្ឋាភិបាល អំពីវឌ្ឍនភាពក្នុងការរៀបចំ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដែលមានរហូតមកដល់ពេលនេះ ។

**កុម្ភៈ**
- ក្រសួងផែនការរៀបចំសិក្ខាសាលាជាតិមួយ ដើម្បីពិភាក្សាលើសេចក្តីព្រាងកែសម្រួលក្រោយកិច្ចប្រជុំអន្តរក្រសួង ។
- ក្រសួងផែនការផ្ញើសេចក្តីព្រាងកែសម្រួលចុងក្រោយ ជូនគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យពិភាក្សា ។

**មីនា-មេសា** កិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី នឹងផ្តល់ការអនុម័តលើសេចក្តីព្រាង ហើយសេចក្តីព្រាង ដែលបានទទួលការអនុម័តរួចហើយ នឹងត្រូវ ផ្ញើទៅជូនរដ្ឋសភានិងព្រឹទ្ធសភា ដើម្បីសុំការឯកភាព និងថ្វាយព្រះមហាក្សត្រ ដើម្បីសុំការឡាយព្រះហស្ថលេខា លើព្រះរាជក្រម សម្រាប់ការប្រកាសឱ្យប្រើផែនការនេះ ជាច្បាប់ ។

**៣០ មេសា** សេចក្តីព្រាងសម្រេចចុងក្រោយ នឹងត្រូវបញ្ជូនទៅធ្វើការបោះពុម្ព បន្ទាប់ពីទទួលការអនុម័តដាក់ឱ្យប្រើជាច្បាប់ ដោយព្រះមហាក្សត្រ រួចហើយ ។

**ឧសភា** ឯកសារបោះពុម្ពរួច នឹងត្រូវធ្វើការបែងចែក ។

៚

# ឧបសម្ព័ន្ធទី២

## ការណែនាំដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អំពីការរៀបចំធាតុចូល

ក. **ការណែនាំទូទៅ**

នៅក្នុងការរៀបចំធាតុចូលដែលត្រូវផ្ញើមកក្រសួងផែនការ សម្រាប់ការរៀបចំ **ផែនការ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវប្រកាន់យកនូវគោលការណ៍ដូចខាងក្រោម :

១. ឆ្នាំ២០០៨ ជាឆ្នាំគោល សម្រាប់ធ្វើការងារនេះ ។

២. ត្រូវយក **របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០០៨ ស្តីពីការអនុវត្ត ផែនការ ២០០៦-២០១០** ជាឯកសារយោង ។

៣. ត្រូវផ្តល់ធាតុចូល ដែលត្រូវបានរៀបចំឡើង ដោយផ្អែកលើព័ត៌មានអំពីវិឌ្ឍភាពទាំងអស់ ដែលមានចែងនៅក្នុង **របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០០៨ ស្តីពីការអនុវត្ត ផែនការ ២០០៦-២០១០** ហើយព័ត៌មានលើសពីនេះ អាចនឹងត្រូវដាក់បញ្ចូលបន្ថែមបាន ប្រសិនបើវាត្រូវបានចាត់ទុកថាជាប្រការចាំបាច់ និង សំខាន់ ។

៤. ចំពោះ ក្រសួង ឬ ស្ថាប័នណា ដែលដឹកនាំ **ក្រុមការងារបច្ចេកទេសចម្រុះរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍** ក្រសួង ឬ ស្ថាប័ន នោះ គប្បីរៀបចំធាតុចូលដែលត្រូវផ្ញើមកក្រសួងផែនការ ដោយមានកិច្ចពិគ្រោះយោបល់ ជាមួយក្រុមការងារបច្ចេកទេសពាក់ព័ន្ធ។

៥. ត្រូវធានាថា ធាតុចូលចុងក្រោយដែលត្រូវផ្ញើមកក្រសួងផែនការ ត្រូវបានឯកភាព ឬ បញ្ជាក់ជាផ្លូវការ ពីថ្នាក់ដឹកនាំនយោបាយ ចាប់ពីថ្នាក់រដ្ឋលេខាធិការ ឡើងទៅ ។

៦. ត្រូវផ្ញើធាតុចូលមកក្រសួងផែនការ **មិនឱ្យហួសថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩** ។

ខ. **ការណែនាំអំពីវិធីសាស្ត្រនៃការរៀបចំធាតុចូល**

១. ត្រូវផ្តល់នូវទិន្នន័យដែលពាក់ព័ន្ធនឹងក្រសួង ឬ ស្ថាប័ន ធៀបទៅនឹង **តារាងសូចនាករសេដ្ឋកិច្ច-សង្គមកិច្ច** សំខាន់ៗរបស់កម្ពុជា និង តារាងពាក់ព័ន្ធ ដែលមានក្នុង **របាយការណ៍ពាក់កណ្តាលអាណត្តិ** តាមទម្រង់ដូចខាងក្រោម :

| ២០០៨<br>ជាក់ស្តែង | ២០០៩<br>ការប៉ាន់ស្មាន | ២០១០<br>ព្យាករណ៍ | ២០១១<br>ព្យាករណ៍ | ២០១២<br>ព្យាករណ៍ | ២០១៣<br>ព្យាករណ៍ |
|---|---|---|---|---|---|
| | | | | | |

***កំណត់សម្គាល់*** : បញ្ចូលនូវកំណត់សម្គាល់ ដោយដាក់លេខ (១), (២), (៣) ធៀបនឹងទិន្នន័យណាមួយ និងផ្តល់នូវការពន្យល់ ប្រសិនបើព័ត៌មានជាក់លាក់ណាមួយ ត្រូវដាក់បញ្ចូលបន្ថែម ជាពិសេស ប្រសិនបើមានការផ្លាស់ប្តូរសំខាន់ៗចំពោះទិន្នន័យទាំងឡាយ ដែលមានចែងក្នុង របាយការណ៍ពាក់កណ្តាលអាណត្តិ ។

២. ត្រូវគូសបញ្ជាក់ដោយត្រួសៗអំពី ស្ថានភាពដែលបានទទួលរងឥទ្ធិពលនៃការប្រែប្រួលមិនទៀងទាត់ របស់សេដ្ឋកិច្ចសាកលលោក ដែលបានកើតឡើង ចាប់តាំងពីឆ្នាំ២០០៧ ហើយកំពុងតែបន្តទៅមុខទៀត (*ដូចជា ការធ្លាក់ចុះនៃសេដ្ឋកិច្ចនៅបណ្តាប្រទេសរីកចម្រើន -- ការធ្លាក់ចុះនៃ លទ្ធភាពទទួលបានឥណទាន និង វិនិយោគ -- ការកើនឡើង ឬ ការធ្លាក់ចុះ នៃថ្លៃទំនិញ -- ។ល។*) និង អំពីស្ថានភាពដែលអាចនឹងកើតមាន នាពេលអនាគត ដោយសារវិបត្តិខាងលើនេះ មកលើវិស័យនីមួយៗ (*ដោយសារ ការបាត់នូវតម្រូវការ ឬ ការកើនឡើងនៃតម្រូវការចំពោះទំនិញទាំងឡាយ -- ការធ្លាក់ចុះនៃចំនួនទេសចរណ៍ -- ។ល។*) ។

៣. ត្រូវផ្តល់ព័ត៌មានស្តីពី ច្បាប់ និង ឯកសារគតិយុត្តិដទៃទៀត (ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរ) ដែលត្រូវបានអនុម័តដាក់ឱ្យប្រើ ក្នុងឆ្នាំ២០០៨ និង ២០០៩ និង ឬ ដែលត្រូវបានគ្រោងទុកជាមុនសម្រាប់ពេលខាងមុខរហូតដល់ចុងឆ្នាំ២០១៣ ។

៤. ត្រូវផ្តល់នូវព័ត៌មានលម្អិតស្តីពី សមិទ្ធផលធំៗដែលសម្រេចបាន និង ប្រការខ្វះខាត ឬ បញ្ហាប្រឈម ទាំងឡាយ ដែលមានតាំងពី ឆ្នាំ២០០៧ មក ។

៥. ត្រូវផ្តល់ព័ត៌មានពី :

- ការសិក្សាឬការស្រាវជ្រាវនានា ដែលបានធ្វើក្នុង ឆ្នាំ២០០៨ និង ២០០៩ និង ដែលត្រូវបានគ្រោង នឹងធ្វើក្នុងពេលអនាគតឆាប់ៗខាងមុខនេះ ព្រមទាំង ទិដ្ឋភាពសំខាន់ៗដែលបានមកពីការងារកំណែទម្រង់ ។
- កម្មវិធីឬផែនការទូទាំងវិស័យ ដែលបានផ្សព្វផ្សាយ ក្នុងឆ្នាំ២០០៨ និង ២០០៩ និងបានរៀបចំសម្រាប់អនាគត ។
- ឯកសារគោលនយោបាយដែលបានរៀបចំរួចហើយ ឬ ដែលបានគ្រោងនឹងរៀបចំក្នុងពេលខាងមុខ ។
- កម្មវិធីនានាសម្រាប់សហគមន៍មូលដ្ឋាន តាមរយៈ ខេត្ត រាជធានី ស្រុក ឃុំ ។
- កម្មវិធីថ្មីៗទាំឡាយ ដែលត្រូវបានចាប់ផ្តើមរួចហើយ ឬ ដែលនឹងត្រូវចាប់ផ្តើម ព្រមទាំង ព័ត៌មានលម្អិតអំពីកម្មវិធីទាំងនោះ ។
- គម្រោងថ្មីៗទាំងឡាយ ដែលត្រូវបានចាប់ផ្តើម ដោយជំនួយពីដៃគូអភិវឌ្ឍន៍ ឬ ដោយ[illegible]
- គំនិតផ្តួចផ្តើមថ្មីៗទាំងឡាយ ។

៦. ត្រូវផ្តល់ព័ត៌មានលម្អិតពី :

- បញ្ហាផ្សេងៗទៀតដែលមិនត្រូវបានលើកឡើងនៅពេលមុន ហើយ ត្រូវបានចាត់ទុកថាជាបញ្ហាសំខាន់ ដែលត្រូវបញ្ចូលនៅក្នុង **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ។
- ការស្នើឡើង អំពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងក្រសួង-ស្ថាប័ននីមួយៗ ដែលត្រូវបានចាត់ទុកថាជាប្រការមានសារៈប្រយោជន៍និងចាំបាច់ ដែលត្រូវបញ្ចូលនៅក្នុង **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ។
- ការស្នើឡើងអំពីធនធានបន្ថែមទាំងឡាយ ដែលត្រូវបានចាត់ទុកថាជាប្រការចាំបាច់ (លើសពីបរិមាណដែលត្រូវបានបែងចែកនៅ **ផយអជ បច្ចុប្បន្នកម្ម ២០០៦-២០១០**) សម្រាប់ការអនុវត្តកម្មវិធីទាំងឡាយរបស់ក្រសួង- ស្ថាប័ននីមួយៗ ។

៧. ប្រសិនបើ និន្នាការនៃការប្រែប្រួលនិងការព្យាករណ៍ទាំងឡាយ ត្រូវបានយល់ថាជាប្រការចាំបាច់ដែលត្រូវរំលេចឡើងឱ្យច្បាស់ នោះក្រាហ្វិកសម្រាប់ទិន្នន័យទាំងអស់ដែលមាន ក្នុងតារាងនៅក្នុងអត្ថបទ និង **ក្នុងតារាងសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗរបស់កម្ពុជា** អាចនឹងដាក់បញ្ចូល នៅក្នុងធាតុចូល ។

៨. **ទម្រង់ទូទៅនៃរបាយការណ៍** : ផ្អែកតាមគ្រប់ចំណុចខាងលើ ត្រូវរៀបចំនូវរបាយការណ៍ទូទៅមួយ ដែលនឹងក្លាយជាផ្នែកមួយនៃ **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** (រៀបចំរបាយការណ៍ ទៅតាមទម្រង់អត្ថបទ ឬ ឧបសម្ព័ន្ធ ដែលមានក្នុង **របាយការណ៍ពាក់កណ្តាលអាណត្តិ**) ។

៚

# ឧបសម្ព័ន្ធទី៣

## ផ្នែកនៃ របាយការណ៍ពាក់កណ្តាលអាណត្តិ នៃ ការអនុវត្ត ផយអជ ២០០៦-២០១០ ដែលក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវពិនិត្យមើល សម្រាប់ការរៀបចំ ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣

| | ក្រសួង-ស្ថាប័ន | ផ្នែកដែលក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវពិនិត្យមើល | | | | | |
|---|---|---|---|---|---|---|---|
| | | តារាងសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ | ជំពូក១ | ជំពូក២ | ជំពូក៣ | ជំពូក៤-៥ | ឧបសម្ព័ន្ធ |
| ១ | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | | | 2.22 | | | |
| ២ | គណៈកម្មាធិការវិនិយោគកម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | | 2.27; 2.66-2.68;2.72 | | | |
| ៣ | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិង យុទ្ធ-ភ័ណ្ឌមិនទាន់ផ្ទុះ និងសង្គ្រោះជនពិការដោយសារមីន | 18.00 | | 2.53 | តារាង 3.2: 40-41 | | |
| ៤ | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 7.00 | | 2.27-2.30; ប្រអប់ 2.3 | | 4.02-04 | |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 8.00 | | 2.40-2.44; 2.54-2.57; តារាង 2.2; ប្រអប់ 2.5 | តារាង 3.2: 4-6; 24-25; | | |
| ៦ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | | 2.39 | | | |
| ៧ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 4.00;5.00;6.00;7.00 | | 2.31-2.38; ប្រអប់ 2.1 និង 2.4; តារាង 2.1 | តារាង 3.1; 3.2 : 32-37 | | 1.1 1.2 និង 1.3 |
| ៨ | ក្រសួងបរិស្ថាន | | | 2.56; 2.57; 2.58 | | | |
| ៩ | ក្រសួងព័ត៌មាន | 15.00 | | 2.66 (ចំណុចមួលចុងក្រោយ) | | | |
| ១០ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | 10.00; 11.00 | | 2.62 (ចំណុចមួលពីរចុង | តារាង 3.2 : 43 | | |

| | ក្រសួង-ស្ថាប័ន | ផ្នែកដែលក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវពិនិត្យមើល | | | | | |
|---|---|---|---|---|---|---|---|
| | | តារាងសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ | ជំពូក១ | ជំពូក២ | ជំពូក៣ | ជំពូក៤-៥ | ឧបសម្ព័ន្ធ |
| | | | | ក្រោយ); 2.64; 2.65; 2.68 | | | |
| ១១ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 8.11 | | 2.51; 2.52; ប្រអប់ 2.6 | | | |
| ១២ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | | 2.72 | តារាង 3.2 : 38 | | |
| ១៣ | ក្រសួងពាណិជ្ជកម្ម | 10.02 | | 2.68-2.69 | | | |
| ១៤ | ក្រសួងអប់រំ យុវជន និងកីឡា | 17.00 | | 2.76-2.78; តារាង 2.4 | តារាង 3.1; 3.2 : 16-20 | | |
| ១៥ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | | 2.27 | | | |
| ១៦ | ក្រសួងសុខាភិបាល | 16.00 | | 2.79-2.83; តារាង 2.5 | តារាង 3.1; 3.2 : 7-15 | | |
| ១៧ | ក្រសួងមហាផ្ទៃ | | | 2.23 | | | |
| ១៨ | ក្រសួងយុត្តិធម៌ | | | 2.21 | | | |
| ១៩ | ក្រសួងផែនការ | 1.00; 3.00 (វ.ជ.ស) | | 2.45 (អ.គ.ជ); 2.86 (វ.ជ.ស) | តារាង 3.2: 1-3; 2.27 (វ.ជ.ស) | | 2.1 ដល់ 2.4 (អ.គ.ជ) |
| ២០ | ក្រសួងទេសចរណ៍ | 14.00 | | 2.70; 2.71 | តារាង 3.2: 39 | | |
| ២១ | ក្រសួងកិច្ចការនារី | 2.00 | | 2.84-2.85 | តារាង 3.2 : 28-30 | | |
| ២២ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 13.00 | | 2.66 | | | |
| ២៣ | ក្រសួងសាធារណៈការ និងដឹកជញ្ជូន | 12.00 | | 2.61-2.62 | តារាង 3.2 : 42 | | |
| ២៤ | ក្រសួងអភិវឌ្ឍន៍ជនបទ | 9.00 | | 2.46-2.50; តារាង 2.3 | តារាង 3.2: 21-23 | | |
| ២៥ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | | 2.74 | | | |

| | ក្រសួង-ស្ថាប័ន | ផ្នែកដែលក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវពិនិត្យមើល | | | | | |
|---|---|---|---|---|---|---|---|
| | | តារាងសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ | ជំពូក១ | ជំពូក២ | ជំពូក៣ | ជំពូក៤-៥ | ឧបសម្ព័ន្ធ |
| ២៦ | ក្រសួងធនធានទឹក និងឧតុនិយម | | | 2.63 | តារាង 3.2 : 26 | | |
| ២៧ | ក្រសួងការពារជាតិ | | | 2.24 | | | |
| ២៨ | ធនាគារជាតិនៃកម្ពុជា | 6.00 | | 2.36 | | | |
| ២៩ | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | | | 2.62 (សូមមើលចំណុចមូល) | | | |
| ៣០ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | | ទាំងអស់ | 2.01-2.17; 2.26; ប្រអប់ 2.1-2.2 | | ជំពូក៤ ទាំងអស់ | |
| ៣១ | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | | | 2.22 | | | |
| ៣២ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | | | 2.20 | | | |
| ៣៣ | ក្រសួងធម្មការ និងកិច្ចការសាសនា | | | 2.39 | | | |
| ៣៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្មនិងជនបទ | | | 2.45 | | | |
| ៣៥ | អង្គភាពប្រឆាំងនឹងអំពើពុករលួយ | | | 2.20 | | | |
| ៣៦ | គណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍន៍ | | | 2.86 | | | |
| ៣៧ | អាជ្ញាធរប្រេងកាតកម្ពុជា | | | 2.65 | | | |
| ៣៨ | ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ | | | 2.21 | | | |
| ៣៩ | អាជ្ញាធរជាតិប្រយុទ្ធនិងជម្ងឺអេដស៍ | | | 2.83 | | | |
| ៤០ | រដ្ឋបាលព្រៃឈើ | 8.08; 8.09; 8.10 | | 2.56; 2.57 | | | |
| ៤១ | រដ្ឋបាលជលផល | 8.05; 8.06; 8.07 | | 2.54; 2.55 | | | |

<u>សម្គាល់</u> : - គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវពិនិត្យមើល និង ផ្តល់នូវ ព័ត៌មាននិងទិន្នន័យត្រឹមត្រូវ នៅផ្នែកនានា ដែលទាក់ទងនឹងក្រសួង-ស្ថាប័ននីមួយៗ ។

- ចំពោះបញ្ហាអន្តរវិស័យ ក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ អាចធ្វើការពិនិត្យផ្តល់អនុសាសន៍បន្ថែម ក្រៅពីចំណុចដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៣នេះ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៥៤៨៦ ពណ.ចបព

ភ្នំពេញថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ផេស៊ីហ្វិក (អេសអ៊ីហ្សេត) អ៊ិនវេសមេន ខូ អិលធីឌី**
**PACIFIC ( SEZ ) INVESTMENT CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 12757/08P** ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ហ្គូ ហៀកហួរ** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **យិន ផាន្នី** អភិបាល
លោកស្រី **ស៊ុម មុនីវត្តី** អភិបាល
លោក **លី ធីរៈ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៦B ផ្លូវលេខ ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវាបញ្ជូន និងដឹកជញ្ជូនទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រង មុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

**ជ.ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ស.ផ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៦៨៧ ពណ.ចបព

ភ្នំពេញថ្ងៃទី១០ ខែ១៣ ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេមបូឌាន ហាវេស ដ្រាយ ហ្វ្រ៊ូត**
CAMBODIAN HARVEST DRIED FRUIT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 12750/08P ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :
- លោកស្រី FROMM MARION ISABEL ប្រធានក្រុមប្រឹក្សាភិបាល
- លោក **ខៀវ សុខេម** អភិបាល
- លោក **ឌុង ប៊ុនធឿន** អភិបាល
- លោក **ចេង ប៊ុនធឿន** អភិបាល
- លោក **អ៊ុក ចំនួនទាសនា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិព្រែកដូង ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

៥- កម្មវត្ថុអាជីវកម្ម :
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ពិសេសផលិត និងនាំចេញចំណីអាហារ
-ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការដឹកជញ្ជូនសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កឹម ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល-ក្រសួងពត៌មាន
- ក្រសួងទេសចរណ៍-ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តកណ្តាល
- មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសទ